## ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
## អភិបូជាសម្ពោធមណ្ឌលនៅទួលតាំង
## ថ្ងៃទី២៨ ឧសភា ២០១៧

អត្ថបទទី១៖ កក ១,១-១១
អត្ថបទទី២៖ អភ ១,១៧-២៣
ដំណឹងល្អ៖ មថ ២៨,១៦-២០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់ សម្រាប់អាគារមណ្ឌលសកម្មភាពថ្មីដែលយើងនឹងសម្ពោធថ្ងៃនេះ។ ថ្ងៃនេះយើងបានស្ដាប់ **សូមអ្នករាល់គ្នាបន្តិចទៀតទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើអ្នករាល់គ្នា ដូច្នេះអ្នករាល់គ្នានឹងធ្វើជាសាក្សីរបស់ខ្ញុំនៅក្នុងស្រុកយេរូសាឡឹម នៅក្នុងស្រុកយូដាទាំងមូល នៅក្នុងស្រុកសាម៉ារី និងនៅក្នុងតំបន់ដាច់ស្រយាលនៃផែនដី។** ពិតមែនព្រះសហាគមន៍របស់យើង បានសាងសង់មូលដ្ឋានគ្រឹះនៅសក្ខីភាពនៃក្រុមគ្រីស្តទូត សម្រាប់យើងដែលជាគ្រីស្តបរិស័ទក្នុងទ្វីបអាស៊ី យើងអាចនិយាយបានថា ព្រះសហាគមន៍របស់យើងបានទទួលមរតក និងសក្ខីពីក្រុមគ្រីស្តទូតៗ និងបានទទួលមរតកនិងសក្ខីភាពពីមរណៈសាក្សី។ ជាពិសេសនៅប្រទេសវៀតណាម ដែលមានមរណៈសាក្សីជាច្រើនបានលះបង់ចោលអ្វីៗទាំងអស់ និងបានបូជាជីវិតដើម្បីឲ្យសព្វថ្ងៃបងប្អូនមានជំនឿរឹងមាំ។ នៅប្រទេសកម្ពុជា យើងកំពុងរៀបចំមរណៈសាក្សីរបស់យើងដែរ ដែលបានសុខចិត្តលះបង់ជីវិតដើម្បីស្រឡាញ់ និងដើម្បីបង្ហាញសក្ខីភាពដល់មនុស្សលោក។ ថ្ងៃនេះព្រះយេស៊ូអញ្ជើញយើង ឲ្យយើងធ្វើពិធីជ្រមុជទឹកក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យគ្រប់ជាតិសាសន៍ធ្វើជាសាវ័ករបស់ព្រះអង្គ។ ថ្ងៃនេះ យើងត្រូវការនឹកឃើញដល់ព្រះសហាគមន៍របស់យើងនៅលើទឹកដីកម្ពុជា ជាព្រះសហាគមន៍ដែលបានចូលនៅក្នុងទុក្ខលំបាកក្នុងសម័យប៉ុលពត ឆ្នាំ១៩៧៥។ ព្រះសហាគមន៍ដែលបានបាត់បង់អ្វីៗទាំងអស់ ទាំងអាគារ ទាំងបងប្អូន ដោយបានប្រើលោកអភិបាល លោកបូជាចារ្យ និងបងស្រីខ្លះៗ ដែលបានទៅតាមវាលស្រែ ដើម្បីធ្វើពលកម្ម។ នៅថ្ងៃទី០១ ខែឧសភា យើងបានរៀបចំអភិបូជាសម្រាប់រំលឹកដល់មរណៈសាក្សីនៃប្រទេសកម្ពុជា យើងដឹងថាសម្រាប់មរណៈសាក្សីយើង គឺយើងនៅសល់តែសក្ខីភាពដោយសារសម្ភារៈយើងគ្មានសល់អ្វីក្រៅពីគ្រែនៅតាំងគោក និងឈើឆ្កាងលោកអភិបាល ដែលជាអនុស្សាវរីយ៍ ដែលជាសញ្ញានៃជីវិតដែលគេបានលះបង់ចោល ក៏ប៉ុន្តែ

យើងមានបងប្អូនគ្រីស្ទបរិស័ទ ដែលបានតស៊ូដើម្បីការពារជំនឿ ដើម្បីឲ្យសព្វថ្ងៃព្រះសហគមន៍របស់យើងក្នុងប្រទេសកម្ពុជាមានជីវិត។ ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៩០ក្នុងប្រទេសកម្ពុជាយើង គ្មានអភិបូជា គ្មានឱកាសដើម្បីជួបជុំគ្នា គ្មានអប់រំជំនឿ ប្រហែលគ្មានពិធីជ្រមុជទឹក អស់រយៈពេលយ៉ាងយូរដែលព្រះសហគមន៍របស់យើង ខ្វះការចិញ្ចឹមពីអគ្គសញ្ញា។ នៅឆ្នាំ១៩៩០ដែលលោកអភិបាលអេមីល បានថ្វាយអភិបូជាដំបូងនៅប្រទេសកម្ពុជា យើងបានប្រមូលគ្រីស្ទបរិស័ទគ្រប់និកាយ ដើម្បីអរព្រះគុណព្រះជាម្ចាស់នៅថ្ងៃបុណ្យចម្លង។

នៅពេលខ្ញុំបានចាប់ផ្តើម បេសកកម្មប្រកាសដំណឹងល្អនៅក្នុងខេត្តតាកែវនិងកំពត ខ្ញុំមានគ្រីស្ទបរិស័ទតែម្នាក់គត់ នៅក្នុងព្រះសហគមន៍ដែលខ្ញុំទទួលខុសត្រូវ។ លោកឪពុកលីនៅកំពតមានតែមួយគ្រួសារគត់ ប៉ុន្តែបន្តិចម្តងៗដល់ឆ្នាំ២០០១យើងមានបងប្អូនខ្មែរប៉ុន្មាននាក់បានទទួលអគ្គសញ្ញាជ្រមុជទឹក ដើម្បីទទួលជីវិតពីព្រះជាម្ចាស់។ ក្នុងរាត្រីបុណ្យចម្លងឆ្នាំ២០១៧នេះ ខ្ញុំបានធ្វើអគ្គសញ្ញាជ្រមុជទឹកដល់បេក្ខជន៦០នាក់ ដែលមានទាំងប្រជាជនធម្មតា មានទាំងយុវជនយុវនារី មានទាំងគ្រូបង្រៀន មានទាំងទាហ៊ាន មានទាំងមនុស្សចាស់ មានទាំងកូនង៉ែត។ ខ្ញុំជាគ្រូគង្វាលសម្រាប់ភូមិភាគភ្នំពេញទាំងមូល ពិតមែននៅក្នុងភូមិភាគរបស់យើងមាន៨០%នៃគ្រីស្ទបរិស័ទជាជនជាតិវៀតណាម និង២០%ជាជនជាតិខ្មែរ។ ប៉ុន្តែយើងមានជំនឿតែមួយ យើងមានពិធីជ្រមុជទឹកតែមួយ យើងមានព្រះបិតាតែមួយ។ នេះជាក្រុមគ្រួសាររបស់យើង ពីមួយថ្ងៃទៅមួយថ្ងៃយើងខិតខំធ្វើដំណើររួមជាមួយគ្នា ដើម្បីកសាងព្រះសហគមន៍របស់ព្រះគ្រីស្ត ដោយបង្ហាញថាពិតមែនយើងជាអង្គតែមួយដូចព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ជាអង្គតែមួយ។ នៅតាមមាត់ទន្លេបាសាក់ និងតាមមាត់ទន្លេមេគង្គ យើងមានសុទ្ធតែព្រះសហគមន៍វៀតណាមធំណាស់ ប៉ុន្តែជាបងប្អូនដែលបានរស់នៅរាប់រយឆ្នាំមកហើយ សព្វថ្ងៃគេរស់នៅក្នុងសង្គមរបស់យើងតែម្តង។ នៅក្នុងព្រះសហគមន៍របស់យើង យើងជាមហាគ្រួសារតែមួយដោយរួមរស់ជាមួយគ្នា ដើម្បីកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ ដូចព្រះយេស៊ូបានប្រកាសឲ្យយើងធ្វើតែម្តង។ ទាំង១៥ព្រះសហគមន៍វៀតណាមដែលមានក្នុងភូមិភាគភ្នំពេញ ពីឆ្នាំ២០១២ខ្ញុំបានបង្កើតសាលាបឋមសិក្សា ដើម្បីឲ្យកូនក្មេងអាចទទួលការសិក្សាថ្នាក់ទី១ទី២ជាភាសាខ្មែរ ជាគ្រឹះដែលណែនាំឲ្យគេចូលនៅក្នុងសាលារដ្ឋពីថ្នាក់ទី៣ទៅ។ ដើម្បីជួយឲ្យកូនក្មេង និងយុវជន

បានចូលរួមគ្រប់សកម្មភាពដែលយើងមាននៅក្នុងភូមិភាគ ដូចជាកាយឫទ្ធិ ក្រុមយុវជន ក្រុមតេរេសា មហាសន្និបាតនានា ការអប់រំ សាលាសន្តយ៉ូស្ទីនអប់រំជំនឿសម្រាប់គ្រីស្តបរិស័ទ បន្ថែមទៀតយើងនឹងរៀបចំសៀវភៅទាំងពីរភាសា គឺភាសាខ្មែរ និងភាសាវៀតណាម ដើម្បីអរព្រះគុណព្រះជាម្ចាស់រួមជាមួយគ្នា។

យើងជាគ្រីស្តបរិស័ទនៅក្នុងភូមិភាគភ្នំពេញ តើយើងធ្វើដូចម្តេចដើម្បីប្រកាសជំនឿរបស់យើង ដើម្បីផ្តល់សក្ខីភាពអំពីព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មគង់នៅសព្វថ្ងៃនៅក្នុងសង្គមរបស់យើង? ទីមួយ **ឲ្យយើងបន្តជាប់ជាមួយព្រះយេស៊ូផ្ទាល់** ខ្ញុំសូមអរគុណបងប្អូនដែលបានយកចិត្តទុកដាក់ចូលព្រះវិហារជារៀងរាល់ថ្ងៃ អធិដ្ឋានអស់ពីកម្លាំងកាយចិត្ត ដើម្បីឲ្យជំនឿរបស់យើងភ្ជាប់ជាមួយព្រះយេស៊ូជានិច្ច។ ទីពីរ **ឲ្យយើងយកចិត្តទុកដាក់រស់នៅជាក្រុមគ្រួសារតែមួយ** នៅក្នុងព្រះសហគមន៍តែមួយដើម្បីបង្ហាញថា ពិតមែនយើងជាបងប្អូនដែលចេះស្រឡាញ់គ្នាទៅវិញទៅមក។ ឥតមានសក្ខីភាពលើសពីសេចក្តីស្រឡាញ់ដែលយើងមានរវាងគ្នាទៅវិញទៅមក និងសេចក្តីស្រឡាញ់ដែលយើងមានសម្រាប់បងប្អូនឯទៀតដែលមានទុក្ខលំបាក ដែលគ្មានសេចក្តីសង្ឃឹម។ ឲ្យយើងយកចិត្តទុកដាក់អធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក ឲ្យយើងយកចិត្តទុកដាក់បង្ហាញសេចក្តីស្រឡាញ់ជាក់ស្តែងដែលយើងមាននៅក្នុងព្រះសហគមន៍របស់យើង ដើម្បីឲ្យព្រះសហគមន៍របស់យើងទោះបីតូចក៏ដោយ តែអាចទៅជាពន្លឺមួយសម្រាប់បងប្អូនឯទៀត។ និងទីបី **នៅក្នុងសក្ខីភាពដែលយើងផ្តល់ជាប្រចាំថ្ងៃនៃជីវិតរបស់យើង** ដើម្បីបង្កើតទំនាក់ទំនង និងដើម្បីយល់ថាពិតមែនលើទឹកដីកម្ពុជាយើងជាគ្រួសារតែមួយ។ និងចុងក្រោយ កុំឲ្យយើងភ្លេច **គំរូនៃមរណៈសាក្សីដែលជាបុព្វបុរសរបស់យើង** ដែលបានលះបង់ចោលអ្វីៗទាំងអស់នៅក្នុងការតស៊ូ ក្នុងការស្រឡាញ់។ ហេតុនេះហើយ នេះជាកម្លាំងមួយសម្រាប់យើង ដោយយល់ថាជីវិតរបស់យើងត្រូវតែតស៊ូសម្រាប់ព្រះយេស៊ូ។

ថ្ងៃនេះពេលយើងទៅតាមកន្លែងរបស់យើងវិញ ឲ្យយើងទុកព្រះបន្ទូលរបស់ព្រះយេស៊ូដែលមានសម្រាប់ក្រុមគ្រីស្តទូត ដែលមានដល់យើងនៅពេលនេះ **ចូរដឹងថាខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ**។ អាម៉ែន។